# ស្គរធំនៅប្រទេសកម្ពុជា

ប្រទេសកម្ពុជាមានស្គរច្រើនប្រភេទរួមមាន៖ ស្គរមហោរធឹក ស្គរភ្លៀង ស្គរអារក្ស ស្គរដៃ ស្គរដី ស្គរថូន ស្គររមនា ស្គរឆៃយ៉ាំ ស្គរយីកេ ស្គរយោល ស្គរក្ងោះ ស្គរឈ្នះ (ក្លង់ឆ្នាក់) ស្គរបាសាក់ ស្គរឡុក ស្គរកាណាំង (ស្គរចាម) ស្គរព្រៃ ស្គររបាំទន្សោង ស្គរប៉ុយសម្ភោរ ស្គរធំ ស្គរភេរី ស្គរជ័យ និងស្គរយាម។ល។

**ស្គរមហោរធឹក** មានវត្តមានតាំងពីសម័យបុរេប្រវត្តិសាស្ត្រមកម៉្លេះ ដែលគេរកឃើញនៅក្នុងតំបន់អាស៊ីមានប្រទេសចិន វៀតណាម ឡាវ ថៃ និងខ្មែរ។ នៅកម្ពុជា ស្គរមហោរធឹកមានប្រើនៅក្នុងព្រះបរមរាជវាំងរហូតដល់ដើមឆ្នាំ១៩៧០ នៅក្នុងព្រះរាជពិធី ដូចជាព្រះរាជាភិសេកព្រះមហាក្សត្រជាដើម នៅក្នុងក្បួនដង្ហែដែលមានអ្នកសែងស្គរបួននាក់ និងអ្នកវាយស្គរម្នាក់។[១] ស្គរមហោរធឹកមួយចំនួនដែលដាក់តាំងនៅសារមន្ទីរជាតិ ក្រុងភ្នំពេញសព្វថ្ងៃមានរាងធំ ហើយទាបស្រដៀងគ្នានឹងត្បាល់បុកស្រូវឬឆ្នាំងធំបុរាណដែលគេដាក់ផ្កាប់។ ស្គរមហោរធឹកធ្វើពីសំរឹទ្ធ ស្ពាន់ ឬទង់ដែង ដោយមានរន្ធក្រវិលត្រចៀកសម្រាប់ចងឬថ្លក់សែងផង។

**ស្គរភ្លៀង** ឬ**ស្គរសុំទឹកភ្លៀង** ជាប្រភេទស្គរបុរេប្រវត្តិសាស្ត្រដូចជាស្គរមហោរធឹកដែរ គ្រាន់តែមានរាងស្គមតូចជាងស្គរមហោរធឹក។ នាសម័យបុរាណ គេប្រើស្គរភ្លៀងសម្រាប់ហៅឬសុំទឹកភ្លៀងនៅពេលមានភាពរាំងស្ងួត។ ក្នុងន័យនេះ គេមានធ្វាក់រូបកង្កែបតូចៗនៅពីលើគែមជុំវិញមុខស្គរ ជាតំណាងឱ្យការសប្បាយរីករាយនៃសត្វកង្កែបនៅពេលមានភ្លៀងធ្លាក់ក៏ដូចជាការទទួលបាននូវទឹកភ្លៀង។

**ស្គរភេរី៖** «ភេរី» មកពីភាសាបាលី, **ភេរិ** មានន័យថា «ស្គរធំ»។ ឯ **ភេរីចរ** មានន័យថា «ការត្រាច់ចរតាមផ្លូវដោយការវាយស្គរ»។[២] ស្គរភេរី មានតួនាទីសំខាន់នៅតាមវត្តអារាមខ្មែរ សម្រាប់ទូងប្រកាសដំណឹងដល់ព្រះសង្ឃនិងពុទ្ធបរិស័ទ ជាពិសេសវត្តអារាមនៅតាមទីជនបទស្រែចម្ការ។

គេប្រើស្គរភេរី ដើម្បីប្រាប់ពីពេលវេលាប្រជុំឬជួបជុំគ្នាក្នុងពិធីសំខាន់អ្វីមួយ។ គេក៏ទូងស្គរភេរី សម្រាប់ជូនដំណឹងដល់អ្នកស្រុកឱ្យប្រញាប់ប្រញាល់រៀបចង្ហាន់ថ្ងៃត្រង់ប្រគេនព្រះសង្ឃដើម្បីឆាន់ទាន់ពេល គេហៅថា៖ ស្គរ១ ស្គរ២ ស្គរ៣ ដែលគេសន្មតគ្នាកំណត់

---

[១] កែវ ២០១១: ១១៣

[២] កែវ ២០១១: ១២៤

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

យកសញ្ញាតាមភូមិនីមួយៗ គឺ៖

ស្គរ១ = ឱ្យដំណឹងលើកទី១

ស្គរ២ = បញ្ចប់ការរៀបចង្ហាន់ប្រគេនព្រះសង្ឃ

ស្គរ៣ = ព្រះសង្ឃឆាន់ហើយ

យើងក៏គួរកត់សម្គាល់ផងដែរថា សព្វថ្ងៃនេះ វត្តមួយចំនួនមិនមានប្រើស្គរគេរីទេ តែគេប្រើជួងឬរគាំងជំនួសវិញ ដើម្បីផ្តល់ជាសញ្ញាជូនដំណឹងដល់ប្រជាជនក៏ដូចជាឧបាសកឧបាសិកានៅក្នុងភូមិនិងចំណុះជើងវត្ត។

ខ្លះហៅស្គរគេរីថា «**ស្គរជ័យ**» ព្រោះមានតួនាទីសម្រាប់ដាស់ស្មារតីកងទ័ពឱ្យរំភើបអង់អាចក្លាហានក្នុងពេលចេញច្បាំង ឬបន្លឺសូរឱ្យកងរំពងនៅពេលត្រឡប់មកពីសមរភូមិវិញ ប្រកបដោយជោគជ័យ។ នៅលើស្បែកស្គរជ័យ គេមានគូរយ័ន្តមន្តអាគមគាថាផង។ នៅក្នុងក្បួនដង្ហែទ័ព ដើម្បីប្រារព្ធរំឭកនៃជ័យជំនះ គេទូងស្គរជ័យឲ្យឮសូរខ្លាំងនិងមានភាពអធឹកអធមដែរ។

ស្គរធំមួយប្រភេទទៀត គេហៅថា «**ស្គរយាម**» គឺគេទូងដើម្បីផ្តល់ដំណឹងពីពេលវេលាដោយនាបុរាណកាល យើងមិនមាននាឡិកាដូចសព្វថ្ងៃសម្រាប់ប្រើប្រាស់ប្រាប់ពីពេលវេលានៅឡើយ។

នាបច្ចុប្បន្នកាល ដូចជាក្នុងសម័យកូវីដ-១៩ យើងប្រើស្គរធំ រួមជាមួយនឹងឧបករណ៍ឯទៀត មានគង ជួង រគាំង ជាដើម សម្រាប់បញ្ជូនសាររំឭក ពញ្ញាក់ស្មារតី និងបណ្តេញគ្រោះឧបទ្រពចង្រៃឱ្យវិនាសចេញឆ្ងាយ ដើម្បីបានសិរីសួស្តីជ័យមង្គលចូលមានដល់ប្រជាជនខ្មែរទូទាំងប្រទេស ក៏ដូចជាប្រជាជនទូទាំងពិភពលោកទាំងមូល។

## ឯកសារយោង

កែវ ណារុំ. (២០១១). *តន្ត្រីនៅប្រទេសខ្មែរ*. ភ្នំពេញ: គ្រឹះស្ថានបោះពុម្ពផ្សាយនគរវត្ត។

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង






អត្ថបទដោយ៖ បណ្ឌិត សំ សំអាង